# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៧៩

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១** : បង្កើតគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ ហៅកាត់ "គ.ជ.ប.អ" ជាជំនួយក្នុងការអនុវត្តន៍ និងតាមដានគោលនយោបាយរបស់រាជរដ្ឋាភិបាល ទាក់ទងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាព ។ល។

មាត្រា ២ : គ.ជ.ប.អ មានគោលដៅដូចតទៅ:

- លើកកំពស់សមត្ថភាពរបស់ប្រជាជន ដើម្បីការអភិវឌ្ឍន៍ ដោយចិរភាព
- ជំរុញឱ្យមានការយល់ដឹងឱ្យបានទូលំទូលាយ អំពីបញ្ហាប្រជាជនទាក់ទិននឹងបរិស្ថាន សុខភាព ការអប់រំ ។ល។
- ផ្តល់លទ្ធភាពពេញលេញដល់ប្រជាជនក្នុងការចូលរួម ដើម្បីកំណត់អាទិភាព និងគោលដៅនានា សំរាប់ការអភិវឌ្ឍន៍
- ជំរុញ និងសំរបសំរួល ក្នុងការបង្កើតផែនការជាតិឱ្យស៊ីជំរៅជាងមុន ពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ នៅក្នុងបណ្តាតំរែងរបស់ក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ២

## សមាសភាព បេសកកម្ម និង ភារកិច្ច

មាត្រា ៣ : គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍន៍ "គ.ជ.ប.អ" មានសមាសភាព ដូចខាងក្រោម:

| | |
|---|---|
| ១- សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬតំណាង | សមាជិក |
| ៤- រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬតំណាង | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឬតំណាង | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឬតំណាង | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង | សមាជិក |
| ១៣- សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក ។ល។ |

**មាត្រា ៤** : **គ.ជ.ប.អ** មានបេសកកម្មដូចតទៅ:

- ធានាកិច្ចសហការ សំរបសំរួល ដ៏សមស្របក្នុងការអនុវត្តន៏ គោលនយោបាយ និងកម្មវិធី ដែលទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ ។
- ត្រួតពិនិត្យតាមដាន និងវាយតំលៃពីគោលនយោបាយទាំងឡាយនិងកម្មវិធីដែលទាក់ទង នឹង ជីវភាពរស់នៅ ការអភិវឌ្ឍន៏ ការការពារ និងលើកកំពស់ សុខមាលភាព ការចូលរួមចំណែករបស់ប្រជាជន ។

**មាត្រា ៥** : ដើម្បីសំរេចបាននូវគោលដៅ និងបេសកកម្មខាងលើនេះ **គ.ជ.ប.អ** មានភារកិច្ចដូចតទៅ:

- ស្រាវជ្រាវ និងផ្សព្វផ្សាយជូនពត៌មាន ស្តីពីសេចក្តីត្រូវការ និង បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងប្រជាជន ជូនទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពនានា ។
- ជួយរាជរដ្ឋាភិបាលក្នុងការតាមដាននិងធ្វើរបាយការណ៏លើបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជននិងការអភិវឌ្ឍន៏ ។
- សំរបសំរួល និងសហប្រតិបត្តិការ រវាងអន្តរក្រសួងក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៏ដើម្បីធានានូវភាពរលូនក្នុងការអនុវត្តន៏គោលនយោបាយ របស់រាជរដ្ឋាភិបាលឲ្យមានប្រសិទ្ធភាព ។
- សំរបសំរួលជាមួយគណៈកម្មការនៃរដ្ឋសភាក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងច្បាប់ប្រជាជន ដើម្បីជាជំនួយក្នុងការសំរេចគោលដៅ កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- សំរបសំរួល និងសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ប្រទេសផ្តល់ជំនួយ សង្គមស៊ីវិល ស្ថាប័នឯកជន ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ដើម្បីធានាភាពជាដៃគូរក្នុងការអនុវត្តន៏គោលនយោបាយរបសរាជរដ្ឋាភិបាល ។
- ទំនាក់ទំនង និងផ្លាស់ប្តូរបទពិសោធន៏ ទស្សនៈជាវិជ្ជមាន និងកម្មវិធីថ្មីៗនៅក្នុងតំបន់ក៏ដូចជាក្រៅតំបន់ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៏ ។
- សំរបសំរួល និងដឹកនាំសិក្ខាសាលា សន្និសីទជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៏ ។
- សំរបសំរួល និងដឹកនាំសិក្ខាសាលា វគ្គបណ្តុះបណ្តាលដល់មន្ត្រីរាជការ តាមក្រសួង តាមតំបន់ និង ខេត្ត-ក្រុង ដើម្បីបង្កើនចំណេះដឹង និងស្វែងយល់អំពីទំនាក់ទំនងរវាងបញ្ហាប្រជាជន និងការអភិវឌ្ឍន៏ ។ល។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

**មាត្រា ៦** : **គ.ជ.ប.អ** មានរចនាសម្ព័ន្ធចាត់តាំង ដើម្បីដំណើរការដូចខាងក្រោម :

- មានអគ្គលេខាធិការដ្ឋានមួយ និងមានការិយាល័យមួយចំនួនសំរាប់បំរើការងារ ដែលមានទីតាំងនៅ ទីស្តីការគណៈរដ្ឋមន្ត្រី ឬ អាចប្តូរទៅកន្លែងដទៃទៀតទៅតាមការចាំបាច់ ។
- អាចបង្កើតគណៈកម្មការជំនាញ និងគណៈកម្មការតំបន់ ដើម្បីធ្វើការមួយរយៈ តាមការកំណត់
- **គ.ជ.ប.អ** អាចមានទីប្រឹក្សាមួយចំនួនដែលមានសមត្ថភាពជំនាញដើម្បីជួយការងារ ។

**មាត្រា ៧** : ប្រធាន ឬអនុប្រធាន មានសិទ្ធិតែងតាំងអ្នកមានជំនាញ - ឥស្សរជន ឬ មន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ និងសមត្ថភាព ដើម្បីសំរួលដំណើរការការងាររបស់គណៈកម្មាធិការជាតិនេះ ។

**មាត្រា ៨** : ប្រធាន ឬអនុប្រធាន គ.ជ.ប.អ អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានគុណសម្បត្តិគ្រប់គ្រាន់មកចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ។

**មាត្រា ៩** : **គ.ជ.ប.អ**មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងដំណើរការការងាររបស់ខ្លួន ។

**មាត្រា ១០** : តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា តំណាងវិទ្យាស្ថានស្រាវជ្រាវពាក់ព័ន្ធនឹងប្រជាជន និងការអភិវឌ្ឍន៍ទាំងក្នុង និងក្រៅប្រទេស អង្គការជំនួយទ្វេភាគី អាចចូលជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការ អញ្ជើញរបស់ **គ.ជ.ប.អ** ។

**មាត្រា ១១** : អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.អ** ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយនាយកប្រតិបត្តិមួយរូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និងនាយកប្រតិបត្តិរងពីររូប ។

**មាត្រា ១២** : ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិនេះ នឹងត្រូវកំនត់ដោយអនុក្រឹត្យមួយដោយឡែក ។

**មាត្រា ១៣** : បុគ្គលិក ឬ អ្នកជំនាញបំរើការងារនៅ **គ.ជ.ប.អ** ត្រូវជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់ **គ.ជ.ប.អ** អាចជួលអ្នកជំនាញ ឬបុគ្គលិកក្រៅក្របខ័ណ្ឌបាន ។

## ជំពូកទី ៤

## ប្រភពធនធាន

**មាត្រា ១៤** : គ.ជ.ប.អ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិក្នុងកញ្ចប់ថវិកានៃទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់បញ្ហាប្រជាជន និងការអភិវឌ្ឍន៍ និងដោយជំនួយពីក្នុងប្រទេស និងក្រៅប្រទេស ។ល។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៦ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្ត នូវព្រះរាជក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ។

**មាត្រា ១៧ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានប្បញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។ល។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០១*

លេខ: ១៥៧២ .ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ៨ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់